# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## MINISTRY OF INDUSTRY, SCIENCE, TECHNOLOGY & INNOVATION

# សៀវភៅថវិកាពលរដ្ឋ ឆ្នាំ២០២៤


*រៀបចំដោយ:*

*-អគ្គនាយកដ្ឋានកិច្ចការទូទៅ*

*-ក្រុមការងារថវិកា និងក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ*

# សៀវភៅថវិកាពលរដ្ឋ ឆ្នាំ២០២៤
# របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## I. ចក្ខុវិស័យ និងបេសកកម្មចម្បងៗ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការដឹកនាំ និងគ្រប់គ្រងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត នៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងនឹងបន្តអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា បន្តធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្ម តាមរយៈការជំរុញលើកទឹកចិត្តការវិនិយោគក្នុងវិស័យឧស្សាហកម្មថ្មីៗ ទំនើប ប្រកបដោយគុណភាព សោភ័ណភាព និងមានតម្លៃបន្ថែមខ្ពស់ មានភាពច្នៃប្រឌិតរស់រវើក និងមានសមត្ថភាពប្រកួតប្រជែងនៅក្នុងទីផ្សារជាតិ និងអន្តរជាតិ ពិសេសឧស្សាហកម្មធុំងធំឡើង ឧស្សាហកម្មអេឡិចត្រូនិច ឧស្សាហកម្មគ្រឿងបន្លាស់ ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មកម្មន្តសាល ផ្សេងទៀត គួបផ្សំនឹងការបន្តជំរុញការអភិវឌ្ឍសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យទៅដល់ទីជនបទ និងការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន ព្រមទាំងបំពេញនូវបេសកកម្មថ្មីដែលរាជរដ្ឋាភិបាលប្រគល់ជូនក្នុងការបង្កើត ជំរុញការអភិវឌ្ឍ និងការសិក្សាស្រាវជ្រាវលើការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ បង្កើនចំណូល និងលើកកម្ពស់សុខុមាលភាពប្រជាជន។

ផ្អែកតាមអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានមុខងារ និងភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមរបស់រាជរដ្ឋាភិបាល ក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត
- ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការអភិវឌ្ឍក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត
- ដឹកនាំ និងគ្រប់គ្រងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងសិប្បកម្ម និងទឹកស្អាតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំគោលនយោបាយនិងកម្មវិធីអភិវឌ្ឍរោងចក្រ សហគ្រាសធុនតូចនិងមធ្យម សិប្បកម្មនិងទឹកស្អាត
- សម្របសម្រួល សហការ និងអនុវត្តការងារសិក្សាស្រាវជ្រាវ ពិសោធន៍ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ នវានុវត្តន៍ ដើម្បីគាំទ្រនិងជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត
- ជំរុញ និងគាំទ្រនវានុវត្តន៍បច្ចេកវិទ្យា តក្កកម្ម គ្រប់គំនិតផ្តួចផ្តើមថ្មីៗ រួមទាំងសហគ្រិនភាពក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត
- គ្រប់គ្រង វាយតម្លៃ ទទួលស្គាល់ និងផ្តល់វិញ្ញាបនបត្រ ប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយបច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយការងារស្តង់ដាររូបនីយកម្ម និងការធានាគុណភាពផលិតផល
- ធ្វើជាអាណាព្យាបាលបច្ចេកទេសលើសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវបានបង្កើតឡើងនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំ គ្រប់គ្រង ផ្សព្វផ្សាយការងារមាត្រាសាស្ត្រ
- រៀបចំ គ្រប់គ្រង និងអនុវត្តនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់ទីក្រុង និងទីប្រជុំជន

- សហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ ស្ថាប័ន អង្គការជាតិនិងអន្តរជាតិនានា រួមទាំងវិស័យ ឯកជន ដើម្បីជំរុញអភិវឌ្ឍន៍វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត។

## II. រចនាសម្ព័ន្ធកម្មវិធី អាទិភាពគោលនយោបាយ និងសកម្មភាពការងារសំខាន់ៗក្នុងឆ្នាំ ២០២៤

| **ឈ្មោះគោលបំណងគោលនយោបាយ** | **ឈ្មោះកម្មវិធីយុទ្ធសាស្ត្រអាទិភាព** | **អនុកម្មវិធី** |
|---|---|---|
| **ជំរុញ និងបង្កើនការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច និងមធ្យម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត ដើម្បីកំណើនសេដ្ឋកិច្ចជាតិ** | <u>កម្មវិធីទី១៖</u> ការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ការវាយតម្លៃទទួលស្គាល់ និងការផ្គត់ផ្គង់ទឹកស្អាត | <u>អនុកម្មវិធីទី១៖</u> ការធ្វើពិពិធកម្មមុខទំនិញឧស្សាហកម្ម |
| | | <u>អនុកម្មវិធីទី២៖</u> ការអភិវឌ្ឍនិងទំនើបកម្មសហគ្រាសធុនតូច និងមធ្យម |
| | | <u>អនុកម្មវិធីទី៣៖</u> អភិវឌ្ឍការងារវាយតម្លៃទទួលស្គាល់ |
| | | <u>អនុកម្មវិធីទី៤៖</u> ការពង្រឹង និងពង្រីកវិសាលភាពការផ្គត់ផ្គង់ទឹកស្អាត |
| | | <u>អនុកម្មវិធីទី៥៖</u> បង្កើនសកម្មភាពអនុវត្តការគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុន តូចមធ្យម និងសិប្បកម្ម និងការផ្គត់ផ្គង់ទឹកស្អាតនៅរាជធានី-ខេត្ត |
| | <u>កម្មវិធីទី២៖</u> ការអភិវឌ្ឍស្តង់ដារ មាត្រាសាស្ត្រជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | <u>អនុកម្មវិធីទី១៖</u> ស្តង់ដារូបនីយកម្ម និងការវាយតម្លៃភាពអនុលោមផលិតផល និងសេវាកម្ម |
| | | <u>អនុកម្មវិធីទី២៖</u> ការអភិវឌ្ឍមាត្រាសាស្ត្រ |
| | | <u>អនុកម្មវិធីទី៣៖</u> បង្កើត និងជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ |
| | | <u>អនុកម្មវិធីទី៤៖</u> សិក្សា ស្រាវជ្រាវ និងអភិវឌ្ឍការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| | | <u>អនុកម្មវិធីទី៥៖</u> បង្កើនសកម្មភាពអនុវត្តការគាំទ្រការអភិវឌ្ឍស្តង់ដារ មាត្រាសាស្ត្រ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅរាជធានី-ខេត្ត |
| | <u>កម្មវិធីទី៣៖</u> ការបង្កើនសេវាទ្រទ្រង់ដំណើរការកិច្ចការទូទៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូចនិងមធ្យម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត | <u>អនុកម្មវិធីទី១៖</u> ការគាំទ្រកិច្ចការទូទៅ, កសាងសមត្ថភាពស្ថាប័ន, ការពង្រឹងយន្តការអធិការកិច្ច និងសវនកម្មផ្ទៃក្នុង |

| | | |
|---|---|---|
| | | <u>**អនុកម្មវិធីទី២៖**</u> ការពង្រឹងសមត្ថភាព និងសេវាគាំទ្ររបស់មន្ទីរ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី-ខេត្ត |

**III. ថវិកាកម្មវិធី**

## ១. ផ្នែកចំណូលមិនមែនសារពើពន្ធ

### ១.១. ក្របខណ្ឌច្បាប់នៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធមានសារៈសំខាន់ក្នុងការគ្រប់គ្រងថវិកាជាតិ ដូចនេះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានយកចិត្តទុកដាក់ការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនេះ ដោយផ្អែកលើឯកសារគតិយុត្ត ដូចខាងក្រោម ៖

- ❑ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(ព្រះរាជក្រមលេខ នស/រកម/០៣២៣/០១២ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣)
- ❑ ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត(ព្រះរាជក្រមលេខ នស/រកម/០៣២៣/០០២ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣)
- ❑ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម(ព្រះរាជក្រមលេខ នស/រកម/០១៣០/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣)
- ❑ ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(ព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២)
- ❑ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០)
- ❑ ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣៧, ៣៨, ១០៩ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម(ព្រះរាជក្រមលេខ នស/រកម/១១១៧/០១៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧)
- ❑ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម(ព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤)
- ❑ ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធអ្នកបង្កាត់ពូជដំណាំ(ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨)
- ❑ អនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ(លេខ ២៨៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣)
- ❑ អនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(លេខ ៧២ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨)
- ❑ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ(លេខ ៥៣២ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧) និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត

### ១.២. ប្រភពចំណូលមិនមែនសារពើពន្ធ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកកវិទ្យា និងនវានុវត្តន៍ មានប្រភពចំណូលធំចំនួន ពីរ ៖

**ក- ចំណូលពីទ្រព្យសម្បត្តិរដ្ឋ**

ចំណូលពីទ្រព្យសម្បត្តិរដ្ឋ មានប្រភពចំណូល ៖

១- ចំណូលពីការជួលទីតាំងរោងចក្រ និងឃ្លាំង តាមកិច្ចសន្យា ដោយមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(បង់១ត្រីមាសម្តង)

២- ចំណូលពីការបង់ភាគលាភ(រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងសៀមរាប) ១ឆ្នាំម្តង តាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣- ចំណូលពីលក់ទ្រព្យសម្បត្តិរដ្ឋ(រោងចក្រ, ចលនទ្រព្យចាស់ៗ)

ចំណូលពីទ្រព្យសម្បត្តិរដ្ឋនេះដែរ ត្រូវបង់ចូលថវិកាជាតិ ១០០ភាគរយ។

**ខ- ចំណូលពីសេវាសាធារណៈ**

១. អង្គភាពមានកម្រងសេវាសាធារណៈ

ក្រសួង ឧ.វ.ប.ន មានអង្គភាពចំនួន ៨ អង្គភាព ដែលមានកម្រងសេវាសាធារណៈ សម្រាប់ធ្វើការផ្តល់សេវាជូនដល់ សេវាករ អាជីវករ និងសាធារណជន តាមយន្តការច្រកចេញចូលតែមួយ មានសេវាសរុប ៨៨៧ សេវា ក្នុងនោះ ៖

ក. **រដ្ឋបាលកណ្តាល ៖**

| | | | |
|---|---|---|---|
| ✓ អគ្គនាយកដ្ឋានឧស្សាហកម្ម | មានសេវាចំនួន | ៩៦ | សេវា |
| ✓ អគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់នៃកម្ពុជា | មានសេវាចំនួន | ២០ | សេវា |
| ✓ អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម | មានសេវាចំនួន | ១១ | សេវា |
| ✓ អគ្គនាយកដ្ឋានទឹកស្អាត | មានសេវាចំនួន | ១២ | សេវា |
| ✓ វិទ្យាស្ថានស្តង់ដារកម្ពុជា | មានសេវាចំនួន | ៥៣ | សេវា |
| ✓ វិទ្យាស្ថានជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | មានសេវាចំនួន | ១៣៨ | សេវា |
| ✓ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | មានសេវាចំនួន | ២០៧ | សេវា |
| ✓ និងសេវាពីការផាកពិន័យ និងទោសទណ្ឌពិន័យជាប្រាក់ | មានសេវាចំនួន | ៣២០ | សេវា |
| ខ. **រដ្ឋបាលរាជធានី ខេត្ត** (អនុវត្តដោយមន្ទីរ ឧ.វ.ប.ន) | មានសេវាចំនួន | ៣០ | សេវា |

២. ការអនុវត្តផ្តល់សេវាសាធារណៈ

❖ ក្រសួង ឧ.វ.ប.ន បានអនុវត្តផ្តល់សេវាសាធារណៈនៅតាមយន្តច្រកចេញចូលតែមួយ ដែលបានបង្កើតឡើង ក្នុងនោះ ៖

- ➢ ច្រកចេញចូលតែមួយនៅក្នុងទីស្តីការក្រសួង(អគ្គនាយកដ្ឋានឧស្សាហកម្ម, អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម និងអគ្គនាយកដ្ឋានទឹកស្អាត)
- ➢ ច្រកចេញចូលតែមួយនៅអគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ក្នុងទីស្តីការក្រសួង
- ➢ ច្រកចេញចូលតែមួយនៅវិទ្យាស្ថានស្តង់ដារ
- ➢ ច្រកចេញចូលតែមួយនៅវិទ្យាស្ថានជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍-វ.ប.ន
- ➢ ច្រកចេញចូលតែមួយនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

❖ ការអនុវត្តនៃការផ្តល់សេវាសាធារណៈ និងការទទួលសាច់ប្រាក់តាមយន្តការច្រកចេញចូលតែមួយ ដោយប្រើប្រាស់បង្កាន់ដៃបង់ប្រភេទ១

❖ ការបង់ចំណូលចូលថវិកាជាតិ ត្រូវបានអនុវត្តន៍តាមប្រព័ន្ធទូទាត់អេឡិចត្រូនិច e-Payment នៅធនាគារដៃគូរ ដោយបញ្ចូលទៅក្នុងប្រព័ន្ធ NRMIS

## ១.៣. គម្រោងចំណូលថវិកាជាតិឆ្នាំ២០២៤

### ក. ផែនការចំណូលប្រចាំឆ្នាំ

| ជំពូក | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ទឹកប្រាក់(ពាន់រៀល) |
|---|---|---|---|
| | | សរុបរួម | ១៤ ៣៧៨ ៨០០ |
| ក. រដ្ឋបាលកំណ្តាល | | | ១៤ ៣៦២ ១០០ |
| ៧៣ | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិរដ្ឋ និងសេវា | ១៤ ២១៦ ១០០ |
| | ៧៣០០៨ | ផលទុនផ្សេងៗទៀត | ៥៧០ ០០០ |
| | ៧៣០២៣ | ផលពីការបង្កើតសហគ្រាស | ៣ ៥០០ ០០០ |
| | ៧៣០៤៨ | ផលពីសេវាផ្សេងៗ | ៦៥ ០០០ |
| | ៧៣០៦៦ | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | ៨០០ ០០០ |
| | ៧៣០៧២ | ការជួលដីមានអគារ | ៥ ២៨១ ១០០ |
| | ៧៣០៨៧ | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | ៤ ០០០ ០០០ |
| ៧៤ | | ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | ១៤០ ០០០ |
| | ៧៤០១២ | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | ១៤០ ០០០ |
| ៧៧ | | ផលផ្សេងៗ និងផលពិសេស | ៦ ០០០ |
| | ៧៧០៥២ | ចំណូលពីការលក់រថយន្ត | ៣ ០០០ |
| | ៧៧០៥៤ | ចំណូលពីការលក់ឧបករណ៍ការិយាល័យ និងគ្រឿងសង្ហារឹម | ៣ ០០០ |
| ក. មន្ទីរ ឧ.វ.ប.ន រាជធានី ខេត្ត | | | ១៦ ៧០០ |

### ខ. ផែនការថវិកាកម្មវិធីប្រចាំឆ្នាំ

| កម្មវិធី | អង្គភាព | ទឹកប្រាក់(ពាន់រៀល) |
|---|---|---|
| | សរុបរួម | ១៤ ៣៧៨ ៨០០ |
| ១.កម្មវិធីទី១ | | ៣ ៧៧៦ ០០០ |
| ១០១.អនុកម្មវិធីទី១ | អគ្គ/ឧស្សាហកម្ម | ២ ៧៧២ ០០០ |
| ១០២.អនុកម្មវិធីទី២ | អគ្គ/សហគ្រាសធុនតូចនិងមធ្យ និងសិប្បកម្ម | ៩៧ ០០០ |
| ១០៣.អនុកម្មវិធីទី៣ | អគ្គ/វាយតម្លៃទទួលស្គាល់នៃកម្ពុជា | ៣០៩ ០០០ |
| ១០៤.អនុកម្មវិធីទី៤ | អគ្គ/ទឹកស្អាត | ៥៩៨ ០០០ |
| ២.កម្មវិធីទី២ | | ៤ ៧២៩ ០០០ |
| ២០១.អនុកម្មវិធីទី១ | វិទ្យាស្ថានស្តង់ដារកម្ពុជា | ១ ៨៩១ ០០ |
| ២០២.អនុកម្មវិធីទី២ | មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | ១ ២៣៤ ០០០ |
| ២០៤.អនុកម្មវិធីទី៤ | វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១ ៦០៤ ០០០ |
| ៣.កម្មវិធីទី៣ | | ៥ ៨៧៣ ៨០០ |
| ៣០១.អនុកម្មវិធីទី១ | អគ្គ/កិច្ចការទូទៅ | ៥ ៨៥៧ ១០០ |
| ៣០២.អនុកម្មវិធីទី២ | មន្ទីរជំនាញ រាជធានី ខេត្ត | ១៦ ៧០០ |

### ១.៤. យន្តការ និងវឌ្ឍនភាព

#### ក. យន្តការ

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបង្កើតក្រុមការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ-ក.គ.ម ដើម្បីដឹកនាំគ្រប់គ្រងចំណូលមិនមែនសារពើពន្ធស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា

- ការប្រមូលចំណូលមិនមែនសារពើពន្ធ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចាំបាច់ត្រូវអនុវត្តវិធានការមួយចំនួនមាន ៖
  - វិធានការ សំដៅដល់កាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលមានកំណត់ក្នុងកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ឬលិខិតគតិយុត្តផ្សេងទៀត។
  - កម្រៃសេវាសាធារណៈរបស់រដ្ឋ ត្រូវស្ថិតនៅក្រោមអានុភាពនៃតារាងតម្លៃដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នសាមី។

#### ខ. វឌ្ឍនភាព

- ក្រសួង ឧ.វ.ប.ន បានកែសម្រួលកម្រងសេវាសាធារណៈនៃប្រកាសអន្តរក្រសួង មុនគេក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីឆ្លើយតបទៅនឹងវិស័យឯកជនទាន់ពេលវេលា និងប្រសិទ្ធភាពលើការផ្តល់សេវា តាមរយៈ ៖
  - ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ(លេខ ៨៣៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣)
  - ប្រកាសអន្តរក្រសួងស្តីពីការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ច(លេខ ៨៣៧ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣)
  - ប្រកាសអន្តរក្រសួងស្តីពីការបែងចែកចំណូលពីសេវាសាធារណៈ និងចំណូលពីការពិន័យ(លេខ ៨៣៨ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣)

- ក្រសួង ឧ.វ.ប.ន បានអនុវត្តកំណែទម្រង់លើការផ្តល់សេវាសាធារណៈ ដោយដាក់អនុវត្តតាមប្រព័ន្ធអនឡាញ ដែលមានលក្ខណៈលឿនជាងមុន និងការបង់ចំណូលចូលថវិកាជាតិត្រូវបានអនុវត្តន៍តាមប្រព័ន្ធទូទាត់អេឡិចត្រូនិច e-Payment នៅធនាគារដៃគូរ ដោយបញ្ចូលទៅក្នុងប្រព័ន្ធ NRMIS

- ការផ្តល់សេវាសាធារណៈមិនសំដៅទៅលើតែកម្រៃសេវា រយៈពេលផ្តល់សេវានោះឡើយ ដែលជាចំណុចសំខាន់ជាងនេះគឺការកែសម្រួលនីតិវិធីផ្សេងៗទៀត ដែលជាតួនាទីរបស់ក្រសួង-ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងវិស័យឯកជន ក៏ត្រូវរួមគ្នាធ្វើដែរ ហើយក្នុងនោះ មានការទាក់ទិនការសម្រួលក្នុងការនាំចូលវត្ថុធាតុដើមសម្រាប់ផលិត ការសម្រួលបែបបទសម្រាប់ការនាំចេញផលិតផលទៅទីផ្សារអន្តរជាតិ ការពង្រឹងស្តង់ដារគុណភាពទំនិញនាំចេញដើម្បីប្រកួតប្រជែង។

## ២. តារាងចំណាយថវិកាថ្នាក់ជាតិ ឆ្នាំ២០២៤

#### ក. តាមចំណាត់ថ្នាក់សេដ្ឋកិច្ច

| ជំពូក | ចំណាត់ថ្នាក់ចំណាយ | ទឹកប្រាក់(លានរៀល) | | |
|---|---|---|---|---|
| | | សរុបរួម | រដ្ឋបាលកណ្តាល | មន្ទីររាជធានីខេត្ត |
| សរុបរួមចំណាយថវិកា | | ៦៩,៩៩២.០ | ៤៦,១៤០.០ | ២៣,៨៥២.០ |
| ៦០ | ការទិញ | ១២,៣១៦.០ | ៧,៧១៨.០ | ៤,៥៩៨.០ |
| ៦១ | សេវាកម្ម | ១៨,៩៥៨១.០ | ១០,៩៣៧.០ | ៧,៦៤៤.០ |

| | | | | |
|---|---|---|---|---|
| ៦៣ | ពន្ធ និងអាករ | ១០២.០ | ៥០.០ | ៥២.០ |
| ៦៤ | បន្ទុកបុគ្គលិក | ៣៨,៥២៦.០ | ២៦,៩៦៨.០ | ១១,៥៥៨.០ |
| ៦៥ | ឧបត្ថម្ភធន | ៤៦៧.០ | ៤៦៧.០ | ០.០ |

## ខ. តាមកម្មវិធី អនុកម្មវិធី

| កូដ កម្មវិធី | បរិយាយ | សរុបឥណទាន (លានរៀល) |
|---|---|---|
| គោលបំណងគោលនយោបាយ៖ ជំរុញ និងបង្កើនការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូចនិងមធ្យម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត ដើម្បីកំណើនសេដ្ឋកិច្ចជាតិ | | ៦៩,៩៩២.០ |
| ១ | **កម្មវិធីទី១៖ ការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ការវាយតម្លៃទទួលស្គាល់ និងការផ្គត់ផ្គង់ទឹកស្អាត** | **៣,៧៨៤.២** |
| ១០១ | អនុកម្មវិធីទី១ ៖ ការធ្វើពិពិធកម្មមុខទំនិញឧស្សាហកម្ម | ៨៧០.០ |
| ១០២ | អនុកម្មវិធីទី២ ៖ ការអភិវឌ្ឍនិងទំនើបកម្មសហគ្រាសធុនតូច និងមធ្យម | ៩១៦.០ |
| ១០៣ | អនុកម្មវិធីទី៣ ៖ អភិវឌ្ឍការងារវាយតម្លៃទទួលស្គាល់ | ៧៩២.០ |
| ១០៤ | អនុកម្មវិធីទី៤ ៖ ការពង្រឹង និងពង្រីកវិសាលភាពការផ្គត់ផ្គង់ទឹកស្អាត | ៧១២.០ |
| ១០៥ | អនុកម្មវិធីទី៥ ៖ បង្កើនសកម្មភាពអនុវត្តការគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងការផ្គត់ផ្គង់ទឹកស្អាតនៅរាជធានី ខេត្ត | ៤៩៤.២ |
| ២ | **កម្មវិធីទី២ ៖ ការអភិវឌ្ឍស្តង់ដារ មាត្រាសាស្ត្រជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | **៤,៥០៨.៥** |
| ២០១ | អនុកម្មវិធីទី១ ៖ ស្តង់ដារូបនីយកម្ម និងការវាយតម្លៃភាពអនុលោមផលិតផល និងសេវាកម្ម | ១,១៥៤.០ |
| ២០២ | អនុកម្មវិធីទី២ ៖ ការអភិវឌ្ឍមាត្រាសាស្ត្រ | ១,២៥៤.៥ |
| ២០៣ | អនុកម្មវិធីទី៣ ៖ បង្កើត និងជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៧៤៧.០ |
| ២០៤ | អនុកម្មវិធីទី៤ ៖ សិក្សា ស្រាវជ្រាវ និងអភិវឌ្ឍការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៨៩៨.០ |
| ២០៥ | អនុកម្មវិធីទី៥ ៖ បង្កើនសកម្មភាពអនុវត្តការគាំទ្រការអភិវឌ្ឍស្តង់ដារ មាត្រាសាស្ត្រ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅរាជធានី-ខេត្ត | ៤៥៥.០ |
| ៣ | **កម្មវិធីទី៣ ៖ ការបង្កើនសេវាទ្រទ្រង់ដំណើរការកិច្ចការទូទៅ ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម  សហគ្រាសធុនតូច និងមធ្យម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត** | **៦១,៦៩៩.៣** |
| ៣០១ | អនុកម្មវិធីទី១ ៖ ការគាំទ្រកិច្ចការទូទៅ, កសាងសមត្ថភាពស្ថាប័ន, ការពង្រឹងយន្តការអធិការកិច្ច និងសវនកម្មផ្ទៃក្នុង | ៣៨,៧៩៦.៥ |
| ៣០២ | អនុកម្មវិធីទី២ ៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្ររបស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី-ខេត្ត | ២២,៩០២.៨ |